មាត្រា ២ ._ ទេសរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងរដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ , ថ្ងៃទី២៣ ខែ កុម្ភៈ ឆ្នាំ១៩៩៩

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

ហ៊ុន សែន

★★★

## ២-សេចក្តីសំរេច

រាជធានីភ្នំពេញ, ថ្ងៃទី ១៧ ខែ កុម្ភៈ ឆ្នាំ ១៩៩៩

### សេចក្តីសំរេចលេខ ១៣ សសរ

### ស្តីពីការកំណត់តំលៃជាវចរន្តអគ្គិសនី

### នៅរាជធានីភ្នំពេញ និងខេត្តកណ្តាល

***

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ របស់ព្រះករុណាព្រះបាទសម្តេច នរោត្តម សីហនុ ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ស្តីពីការតែងតាំងរាជរដ្ឋាភិបាលថ្មី
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញសំណើរួមរបស់ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងរដ្ឋមន្ត្រីក្រសួងឧស្សាហកម្មរ៉ែ និងថាមពល
- យោងស្មារតីសម័យប្រជុំពេញអង្គរបស់គណៈរដ្ឋមន្ត្រី នាថ្ងៃទី១៥ ខែមករា ឆ្នាំ១៩៩៩

### សំរេច

មាត្រា ១ ._ កំណត់តំលៃជាវចរន្តអគ្គិសនី នៅរាជធានីភ្នំពេញ និងនៅខេត្តកណ្តាលសំរាប់អតិថិជនទាំងអស់ទៅតាមប្រភេទ និងថ្លៃដូចខាងក្រោម ៖

១-អតិថិជន លំនៅដ្ឋាន ៖ តំលៃលក់ ៣៥០រៀល ក្នុង០១គីឡូវ៉ាត់ម៉ោង ត្រូវបានរក្សាទុកដដែល។

២-អតិថិជនឧស្សាហកម្ម និងសិប្បកម្ម ៖ តំលៃលក់ ១៧ សេនដុល្លារអាមេរិក ក្នុង០១គីឡូវ៉ាត់ម៉ោង ។

៣-អតិថិជន ពាណិជ្ជកម្ម អាជីវកម្ម និងសេវាកម្មផ្សេងៗ : តំលៃលក់ ១៧ សេនដុល្លារអាមេរិក ក្នុង ០១ គីឡូវ៉ាត់ម៉ោង ។

៤-អតិថិជនស្ថានទូត សណ្ឋាគារ ផ្ទះជួលអោយជនបរទេស : តំលៃលក់ ២១សេនដុល្លារអាមេរិក ក្នុង ០១គីឡូវ៉ាត់ម៉ោង ។

៥-អតិថិជន អង្គភាពរដ្ឋបាលបុព្វហេតុ : តំលៃលក់ ៧០០ រៀល ក្នុង ០១ គីឡូវ៉ាត់ម៉ោង ។

មាត្រា ២ ._ សេចក្តីសំរេចរបស់រាជរដ្ឋាភិបាល ស្តីពីការកំណត់ថ្លៃជាវអគ្គិសនីពីមុន និងបទបញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីសេចក្តីសំរេចនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

មាត្រា ៣ ._ ទេសរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងឧស្សាហកម្មរ៉ែ និងថាមពល រដ្ឋមន្ត្រីក្រសួងផែនការ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រី រដ្ឋលេខាធិការនៃក្រសួង - ស្ថាប័នពាក់ព័ន្ធ ប្រតិភូរាជរដ្ឋាភិបាលប្រចាំរាជធានីភ្នំពេញ អភិបាលខេត្តកណ្តាល និងអគ្គិសនីកម្ពុជា មានភារកិច្ចអនុវត្តសេចក្តីសំរេចនេះ អោយមានប្រសិទ្ធភាពចាប់ពីថ្ងៃទី ០១ ខែ មីនា ឆ្នាំ ១៩៩៩ តទៅ ។

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

ហ៊ុន សែន

★★★

រាជធានីភ្នំពេញ, ថ្ងៃទី ១៧ ខែ កុម្ភៈ ឆ្នាំ ១៩៩៩

## សេចក្តីសំរេចលេខ ១៨ សសរ

## ស្តីពីការកំណត់តំលៃជាវចរន្តអគ្គិសនី

## នៅ ក្រុងព្រះសីហនុ

***

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ របស់ព្រះករុណាព្រះបាទសម្តេច នរោត្តម សីហនុ ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ស្តីពីការតែងតាំងរាជរដ្ឋាភិបាលថ្មី
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី